ក្រសួងមុខងារសាធារណៈ

# លទ្ធផលការងារ

# បញ្ហាប្រឈម និងទិសដៅការងារបន្ត

# របស់ក្រុមការងារយេនឌ័រ

## បង្ហាញដោយ ឯកឧត្តម ជុក មុន្នី

## អនុរដ្ឋលេខាធិការ និងជាប្រធាន

## ក្រុមការងារយេនឌ័រ នៃក្រសួងមុខងារសាធារណៈ

# មាតិកា

I. លទ្ធផលការងារ

II. អនុសាសន៍សំខាន់ៗរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី

III. បញ្ហាប្រឈម

IV. ទិសដៅការងារបន្ត

- កម្មវិធីជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ

# I. លទ្ធផល

- បានរៀបចំបោះពុម្ពផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈដំណាក់កាលទី៣ ឆ្នាំ២០១៤-២០១៨ ចំនួន ២៥០០ច្បាប់ ក្រោមការឧបត្ថម្ភគាំទ្ររបស់ UNDP
- បានរៀបចំសិក្ខាសាលាចំនួន០៦លើក និងវគ្គបណ្តុះបណ្តាលចំនួន០៥លើក មានអ្នកចូលរួមសរុបចំនួន ៩៧៦នាក់ ក្នុងនោះស្ត្រីចំនួន ៥២៦នាក់ ក្រោមប្រធានបទ ដូចខាងក្រោម៖

  (១) ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ ដំណាក់កាលទី៣ ឆ្នាំ២០១៤-២០១៨ នៅថ្នាក់ជាតិចំនួន០១លើក និងថ្នាក់ក្រោមជាតិចំនួន០៣លើក

  (២)ការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈដល់មន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌថ្មី

# I. លទ្ធផល

(៣)ពង្រឹងសមត្ថភាពអ្នកសម្របសម្រួល

(៤)ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ

(៥)សេចក្តីព្រាងគោលនយោបាយ និងយុទ្ធសាស្រ្តជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ

(៦)ថ្នាក់ដឹកនាំជាស្ត្រីដែលមានមុខងារជារដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការចំនួន ៨៤នាក់ ដែលមានរយៈពេល១០០ម៉ោងនៅសាលាភូមិន្ទរដ្ឋបាល

- បានចុះMOUជាមួយអង្គការ UN WOMEN ដើម្បីអនុវត្តគម្រោងស្តីពី "ការលើកកម្ពស់ភាពជាតំណាងរបស់ស្ត្រី នៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្តក្នុងវិស័យមុខងារសាធារណៈ" និងបាននិងកំពុងរៀបចំសេចក្តីព្រាងកម្មវិធីជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ ឆ្នាំ២០១៨-២០២៣ ដោយបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ចំនួន ០៣ លើក និងកិច្ចប្រជុំជាមួយអង្គការ UN WOMEN ចំនួន ១២លើក

# I. លទ្ធផល

- បានយកចិត្តទុកដាក់ខ្ពស់លើការបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្ត្រី ដោយបានបញ្ជូនមន្ត្រីរាជការជាស្ត្រីមួយរូបទៅបណ្តុះបណ្តាលនៅប្រទេសកូរ៉េខាងត្បូង និងបានប្រជុំពិភាក្សាការងារជាមួយអង្គការ Open Institute ដើម្បីត្រៀមអនុវត្តគម្រោងបណ្តុះបណ្តាលសម្រាប់មន្ត្រីរាជការស៊ីវិលជាស្ត្រីលើផ្នែកព័ត៌មានវិទ្យា
- បានប្រជុំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធការងារយេនឌ័រ ក្នុងនោះបានប្រជុំជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ចំនួន ០៥ លើក គជអប ចំនួន ០១ លើក និង Open Institute ចំនួន ០១ លើក

# I. លទ្ធផល

- បានធ្វើបទបង្ហាញស្តីពី

(១) ទស្សនវិស័យនៃការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ និងគោលការណ៍ណែនាំសំខាន់ៗ នៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

(២) ការលើកកម្ពស់ភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ នៅអង្គការវិទ្យាស្ថានបើកទូលាយ (Open Institute)

(៣)យេនឌ័រក្នុងវិស័យមុខងារសាធារណៈ ដល់មន្ត្រីរាជការ និងថ្នាក់ដឹកនាំក្រសួងទេសចរណ៍

(៤)ក្របខ័ណ្ឌគោលនយោបាយលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ នៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

(៥)ការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

# I. លទ្ធផល

(៦)ក្របខ័ណ្ឌគោលនយោបាយលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈនៅក្រសួងអប់រំ យុវជន និងកីឡា

- បានចុះតាមដានវាយតម្លៃលើការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ(CEDAW)
- អនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាល និងច្បាប់ជាតិពាក់ព័ន្ធនឹងការលើកកម្ពស់ស្ថានភាព ជីវភាព ឋានៈ តួនាទី និងសុខុមាលភាពស្ត្រី ជាមួយប្រតិភូក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នៅខេត្តកំពតកំពង់ស្ពឺ ពោធិ៍សាត់ ព្រះសីហនុ ព្រៃវែង និងកំពង់ចាម
- បានចូលរួមនិងសហការរៀបចំពិធីអបអរសាទរ ទិវាអន្តរជាតិនារី៨ មីនា ជារៀងរាល់ឆ្នាំ។




*ក្រាហ្វិកទី១៖ ភាគរយមន្ត្រីរាជការស៊ីវិលដែលមានមុខតំណែងចាប់ពីថ្នាក់ការិយាល័យក្រុង/ស្រុក/ខណ្ឌ រហូតដល់ថ្នាក់អគ្គនាយក និងថ្នាក់ស្មើ ឆ្នាំ ២០១៣-២០១៧*




*ក្រាហ្វិកទី២៖ ភាគរយមន្ត្រីរាជការស៊ីវិលសរុប ឆ្នាំ២០១៣-២០១៧*

# II. អនុសាសន៍សំខាន់ៗរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី

អនុសាសន៍ទី២

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ត្រូវបន្តចុះសិក្សាស្វែងយល់អំពីឧបសគ្គរារាំងក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ស្ត្រី ដែលមានតួនាទីក្នុងការធ្វើសេចក្តីសម្រេចទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងបន្តសិក្សាស្វែងយល់អំពីគោលការណ៍សំខាន់ៗ ដែលចាំបាច់សម្រាប់ការពង្រឹងសមត្ថភាពរបស់ស្ត្រី ។

អនុសាសន៍ទី៣

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) ក្រសួងមហាផ្ទៃ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី និងក្រសួងមុខងារសាធារណៈ ត្រូវបង្កើនកិច្ចសហការក្នុងការបន្ត អភិវឌ្ឍសមត្ថភាពដល់ស្ត្រីជាថ្នាក់ដឹកនាំថ្នាក់ក្រោមជាតិទាក់ទងនឹងផ្នែកមគ្គុទេសន៍ភាព ច្បាប់ និងបទប្បញ្ញត្តិនានា និងរៀបចំវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសសម្រាប់ថ្នាក់ដឹកនាំនារី

## II. អនុសាសន៍សំខាន់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី

ដើម្បីជួយឲ្យពួកគេអាចបំពេញតួនាទីនិងភារកិច្ចដែលរាជរដ្ឋាភិបាលប្រគល់ជូនឲ្យកាន់តែប្រសើរឡើង ព្រមទាំងរៀបចំវគ្គពិសេសសម្រាប់ស្ត្រីនិងស្ត្រីវ័យក្មេង ហើយវាយតម្លៃលទ្ធផលឲ្យបានជាក់លាក់ ។

អនុសាសន៍ទី៩.ក

គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី ត្រូវ៖

- បន្តយកចិត្តទុកដាក់ក្នុងការបង្កើនចំនួនមន្ត្រីរាជការជាស្ត្រីបន្ថែមទៀត និងការតែងតាំងមុខតំណែង ឲ្យមានតំណាងស្ត្រីនៅគ្រប់រចនាសម្ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងជួយឧបត្ថម្ភគាំទ្រ ទាំងស្មារតី មធ្យោបាយ ថវិកា និងផ្តល់ឱកាសឲ្យមានសំឡេងស្ត្រីចូលរួមយោបល់ក្នុងការសម្រេចតែងតាំង
- ពិនិត្យការតែងតាំងមន្ត្រីរាជការជាស្ត្រីដែលមានសមត្ថភាពជំនួសមន្ត្រីជាស្ត្រីចូលនិវត្តន៍ ដែលរួមចំណែក រក្សាបាននូវកំណើនចំនួនស្ត្រីក្នុងតួនាទីមានសិទ្ធិសម្រេច

## II. អនុសាសន៍សំខាន់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី

- បង្កើនសមត្ថភាពមន្ត្រីរាជការស៊ីវិលជាស្ត្រីតាមរយៈវគ្គបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស

- យកចិត្តទុកដាក់ជ្រើសរើសមន្ត្រីរាជការស៊ីវិលជាស្ត្រីសម្រាប់បន្តវេនលើគ្រប់វិស័យ ជាពិសេស នៅថ្នាក់ក្រោមជាតិ

- យកចិត្តទុកដាក់ចំពោះមន្ត្រីរាជការស៊ីវិលជាស្ត្រីមុនពេលចូលនិវត្តន៍ ដោយដំឡើងឋានន្តរស័ក្តិ និងថ្នាក់ក្នុងប្រភេទក្របខណ្ឌរបស់ខ្លួន តាមអតីតភាពការងារឲ្យស្របតាមគោលការណ៍ ។

## III. បញ្ហាប្រឈម

- ខ្វះថវិកាគាំទ្រប្រតិបត្តិការ សកម្មភាពការងារ
- ខ្វះធនធាន មធ្យោបាយ និងសម្ភារគាំទ្រការងារយេនឌ័រ
- សមត្ថភាពក្រុមការងារនៅមានកម្រិត
- ទំនាក់ទំនង  និងបណ្តាញការងារជាមួយអ្នកពាក់ព័ន្ធពុំទាន់បានល្អ
- ការទទួលព័ត៌មាន និងលិខិតពាក់ព័ន្ធពុំទាន់ពេលវេលា
- ថ្នាក់ដឹកនាំ  និងមន្ត្រីរាជការមួយចំនួននៅមានទស្សនៈរើសអើងចំពោះមន្ត្រីរាជការស៊ីវិលជាស្ត្រីនៅឡើយ។

## III. ទិសដៅការងារបន្ត

- បន្តរៀបចំសេចក្តីព្រាងកម្មវិធីជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ ឆ្នាំ២០១៨-២០២៣
- បន្តផ្សព្វផ្សាយ អប់រំ និងបណ្តុះបណ្តាលការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ។

# សេចក្តីព្រាងកម្មវិធីជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ

## ចក្ខុវិស័យ

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេស ដែលមានស្ត្រី និងបុរសចូលរួម និងភាពជាតំណាងប្រកបដោយសមភាពនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងវិស័យមុខងារសាធារណៈនៅគ្រប់កម្រិត

# សេចក្តីព្រាងកម្មវិធីជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ

## គោលបំណង

ស្ត្រីនៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្តនៅក្នុងវិស័យមុខងារសាធារណៈ បានកើនឡើង និងអ្នកដឹកនាំជាស្ត្រីត្រូវបានបង្កើនភាពអង់អាច ដើម្បីចូលរួមឱ្យបានស៊ីជម្រៅជាអ្នកធ្វើសេចក្តីសម្រេចចិត្ត នៅគ្រប់កម្រិត ក្នុងវិស័យមុខងារសាធារណៈ

# សេចក្តីព្រាងកម្មវិធីជាតិលើកកម្ពស់ស្ត្រីតាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ

## លទ្ធផល

១-ស្ត្រីនឹងមានចំនួន ២៥-៣០% នៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្តនៅក្នុងវិស័យមុខងារសាធារណៈ ត្រឹមឆ្នាំ២០២៣

២-មន្ត្រីរាជការស៊ីវិលជាស្ត្រីនឹងកើនឡើងដល់៤៧ភាគរយក្នុងចំណោមមន្ត្រីរាជការស៊ីវិលនៅទូទាំងប្រទេស ត្រឹមឆ្នាំ២០២៣

# សេចក្តីព្រាងកម្មវិធីជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ

## គោលដៅ

១-បង្កើនចំនួននិងសមាមាត្រនៃមន្ត្រីរាជការស៊ីវិលជាស្ត្រី និងស្ត្រីក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្តក្នុងវិស័យមុខងារសាធារណៈ តាមរយៈសកម្មភាពជាវិជ្ជមានក្នុងការជ្រើសរើស ការតែងតាំង និងការដំឡើងថ្នាក់-ឋានន្តរស័ក្តិដល់ស្ត្រីក្នុងវិស័យមុខងារសាធារណៈ

# សេចក្តីព្រាងកម្មវិធីជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ

## គោលដៅ

២-បង្កើនសមត្ថភាពដឹកនាំនិងគ្រប់គ្រងរបស់ស្ត្រីក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្ត និងស្ត្រីនៅក្នុងវិស័យមុខងារសាធារណៈតាមរយៈគំនិតផ្តួចផ្តើម និងកម្មវិធីសម្រាប់ការអភិវឌ្ឍសមត្ថភាពស្ត្រីជាគោលដៅនិងត្រូវពង្រឹងបន្ថែម

# សេចក្តីព្រាងកម្មវិធីជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំ ក្នុងវិស័យមុខងារសាធារណៈ

## គោលដៅ

៣-បង្កើនបរិយាកាសការងារប្រកបដោយភាពវិជ្ជមាន និងធានាឱ្យមានប្រព័ន្ធគាំទ្រសម្រាប់ស្ត្រីក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្ត និងស្ត្រីគ្រប់រូបនៅក្នុងវិស័យមុខងារសាធារណៈ

# សេចក្តីព្រាងកម្មវិធីជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ

## គោលដៅ

៤-ធានាឲ្យមានប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃប្រកបដោយប្រសិទ្ធភាព ដែលត្រូវបានប្រើប្រាស់ដើម្បីធ្វើការពិនិត្យឡើងវិញ និងរាយការណ៍អំពីការអនុវត្តកម្មវិធីជាតិ

# សេចក្តីព្រាងកម្មវិធីជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ

## យុទ្ធសាស្ត្រ

**យុទ្ធសាស្ត្រទី១៖** សកម្មភាពជាវិជ្ជមានសម្រាប់ការជ្រើសរើស ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការតែងតាំងមុខតំណែងដល់ស្ត្រីក្នុងវិស័យមុខងារសាធារណៈ

**យុទ្ធសាស្ត្រទី២៖** ការអភិវឌ្ឍសមត្ថភាពស្ត្រី ដែលកំពុងកាន់តំណែងជាអ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកដែលមានសក្តានុពលដើម្បីបំពេញតួនាទីធ្វើសេចក្តីសម្រេចចិត្តក្នុងវិស័យមុខងារសាធារណៈ

# សេចក្តីព្រាងកម្មវិធីជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ

## យុទ្ធសាស្ត្រ

យុទ្ធសាស្ត្រទី៣៖ បរិយាកាសការងារ និងប្រព័ន្ធគាំទ្រ

យុទ្ធសាស្ត្រទី៤៖ ការពិនិត្យតាមដាន និងការវាយតម្លៃការអនុវត្តកម្មវិធីជាតិ



សកម្មភាពរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីកម្មវិធីជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំ
ក្នុងវិស័យមុខងារសាធារណៈ ឆ្នាំ២០១៨-២០២៣ នៅខេត្តមណ្ឌលគិរី
នាថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៧



សកម្មភាពរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីកម្មវិធីជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំ
ក្នុងវិស័យមុខងារសាធារណៈ ឆ្នាំ២០១៨-២០២៣ នៅខេត្តមណ្ឌលគិរី
នាថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៧

យើងរួមគ្នាគាំទ្រការលើកកម្ពស់សមភាពយេនឌ័រ

ក្នុងវិស័យមុខងារសាធារណៈ !

ជួយមន្ត្រីរាជការស៊ីវិលជាស្ត្រី គឺជួយខ្លួនឯង

និងសង្គមជាតិ !

សូមអរគុណ!